<u>ការជូនដំណឹងរបស់លោក អៀង សារី ទៅអង្គជំនុំជម្រះសាលាដំបូងថា គាត់នឹងមិនផ្តល់សក្ខីកម្មទេ</u>

អនុលោមតាមមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជា, មាត្រា ៣៣ថ្មី និងមាត្រា ៣៥ថ្មី នៃច្បាប់បង្កើត អវតក និង មាត្រា ១២(២) នៃកិច្ចព្រមព្រៀង និងវិធាន ២១(១)(ឃ) នៃវិធានផ្ទៃក្នុង និងមាត្រា ១៤(៣)(ឆ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្ស និងសិទ្ធិនយោបាយ, ខ្ញុំ (អៀង សារី) មានសិទ្ធិនៅស្ងៀមមិនឆ្លើយតបនៅគ្រប់ដំណាក់កាលនីតិវិធីទាំងអស់ ។ ហេតុដូច្នេះ ខ្ញុំសូមធ្វើការបញ្ជាក់ដូចខាងក្រោម៖

1. បច្ចុប្បន្ននេះខ្ញុំត្រូវបានតំណាងឱ្យដោយមេធាវីការពារក្តី ។
2. ខ្ញុំត្រូវបានគេជូនដំណឹងអំពីការចោទប្រកាន់ និងយល់ពីបទចោទប្រកាន់ប្រឆាំងនឹងខ្លួនខ្ញុំ ។
3. ខ្ញុំត្រូវបានគេជូនដំណឹងអំពីទីកន្លែង និងការជិតមកដល់នៃការជំនុំជម្រះក្តីរបស់ខ្ញុំ ។
4. ខ្ញុំដឹងអំពីសិទ្ធិរបស់ខ្ញុំក្នុងការចូលរួមការពារដោយខ្លួនឯងផ្ទាល់ ។
5. ខ្ញុំដឹងអំពីសិទ្ធិរបស់ខ្ញុំក្នុងការនៅស្ងៀមមិនឆ្លើយតបនៅគ្រប់សវនាការទាំងអស់នៅ អវតក ។
6. ខ្ញុំដឹងអំពីសិទ្ធិរបស់ខ្ញុំដែលត្រូវទទួលបានការកាត់សេចក្តីដោយមានវត្តមានរបស់ខ្ញុំ ។
7. ខ្ញុំដឹងអំពីសិទ្ធិរបស់ខ្ញុំក្នុងការសួរចម្លើយ ឬសុំឱ្យសួរចម្លើយទៅលើសាក្សីដាក់បន្ទុក និងសុំឱ្យមានវត្តមានសាក្សីទាំងនោះ ក្នុងនាមរបស់ខ្ញុំ ។
8. ខ្ញុំដឹងអំពីសិទ្ធិរបស់ខ្ញុំក្នុងការទទួលបាននូវពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារខ្លួន ។
9. ខ្ញុំដឹងអំពីសិទ្ធិរបស់ខ្ញុំក្នុងការទទួលបានការជំនុំជម្រះដោយមិនពន្យារពេល ។

ដោយបានយល់ដឹងយ៉ាងពេញលេញអំពីដំណើរការនីតិវិធីប្រឆាំងនឹងរូបខ្ញុំ និងសិទ្ធិរបស់ខ្ញុំដូចបានបញ្ជាក់ពីខាងលើ ខ្ញុំសូមជូនដំណឹងដោយស្ម័គ្រចិត្ត ដោយចេតនា និងយ៉ាងច្បាស់លាស់ដល់អង្គជំនុំជម្រះសាលាដំបូងថា ខ្ញុំនឹងមិនផ្តល់សក្ខីកម្មទេ រួមទាំងការឆ្លើយតបទៅនឹងសំណួរណាមួយមកកាន់រូបខ្ញុំ ក្នុងអំឡុងពេលសវនាការ ឬសវនាការជាដំណាក់កាលៗនៅក្នុងករណី ០០២។ សហមេធាវីរបស់ខ្ញុំនឹងមានវត្តមានក្នុងអំឡុងពេលសវនាការដើម្បីធានាការអនុវត្តដ៏មានប្រសិទ្ធិភាពនូវសិទ្ធិរបស់ខ្ញុំក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ។

សូមលោក/ស្រីចៅក្រមនៃទទួលយកការជូនដំណឹងនេះដោយក្តីគោរព ។

អៀង សារី
ករណី ០០២
ថ្ងៃទី២៤ ខែតុលា ឆ្នាំ ២០១១